ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៣០១ ព.ណ.ករ

ភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា៖ យោងតាមប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម នឹងចាប់ផ្តើមអនុវត្តប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៥ នេះតទៅ តារាងតម្លៃសេវាសាធារណៈនឹងបិទផ្សាយនៅទីស្តីការក្រសួង តាមបណ្តានាយកដ្ឋានជំនាញ បញ្ជរបង់ប្រាក់រួម និងតាមរយៈគេហទំព័ររបស់ក្រសួង www.moc.gov.kh. ។

ដោយឡែកសេវាមួយចំនួន ដែលពាក់ព័ន្ធជាមួយមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌគោលដៅត្រូវរក្សាទុករង់ចាំសេចក្តីណែនាំរបស់ក្រសួង។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**តប.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**

ឃឹម_សិរីវឌ្ឍ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469